# តាមដានសេដ្ឋកិច្ច - ស្ថានភាពក្រៅប្រទេស[១]

ផ្នែកនេះ បង្ហាញពីនិន្នាការសូចនាករសេដ្ឋកិច្ចពិភពលោក និងសេដ្ឋកិច្ចនៅអាស៊ីបូព៌ា។

## កំណើនសេដ្ឋកិច្ចពិភពលោក

បណ្ដាប្រទេសនៅអាស៊ីអាគ្នេយ៍ អាស៊ីបូព៌ា និងប្រទេសឧស្សាហកម្ម បានព្យាយាមផ្ដល់សន្ទុះឡើងវិញ ដល់សេដ្ឋកិច្ចរបស់ខ្លួន ចាប់តាំងពីពេលកើតមានវិបត្តិហិរញ្ញវត្ថុសាកលមក។ បើធៀបនឹងត្រីមាសមុន និងកាលពីមួយឆ្នាំមុន ស្ថានភាពសេដ្ឋកិច្ចនៅត្រីមាសទី២ ឆ្នាំនេះ គួរឲ្យបារម្ភគួរសម ដោយសារប្រទេសជាច្រើនមានកំណើនយឺត។

នៅត្រីមាសទី២ កំណើន ផសស ពិតនៅម៉ាឡេស៊ី ធ្លាក់ចុះមកត្រឹម ៤% ធៀបនឹង ៨,៩% កាលពីមួយឆ្នាំមុន។ កំណើន ផសស នៅសិង្ហបុរី ធ្លាក់ចុះមកត្រឹម ០,៩% ធៀបនឹង ១៨,៧% ដែលជាអត្រាខ្ពស់បំផុតចាប់តាំងពីឆ្នាំ២០០៦។ សេដ្ឋកិច្ចប្រទេសថៃបន្ដថយកំណើន ដោយធ្លាក់មកត្រឹម ២,៦% ធៀបនឹង ៩,២% កាលពីមួយឆ្នាំមុន ដោយសារជាចម្បងស្ថានភាពនយោបាយដែលបានប៉ះពាល់ដល់ទំនុកចិត្ត និងវិនិយោគឯកជន ព្រមទាំងទឹកជំនន់ដែលបានប៉ះពាល់ដល់ ប្រជាជនរាប់ពាន់គ្រួសារ។ ទោះបីមានកំណើនយឺតជាងមុនក្ដី ក៏ចិន និងហុងកុង នៅតែសម្រេចលទ្ធផលល្អ ដោយមានកំណើន ផសស ពិត ៩,៥% និង ៥,១% រៀងគ្នា ធៀបនឹងមួយឆ្នាំមុន។ កំណើន ផសស នៅកូរ៉េខាងត្បូង ធ្លាក់ចុះពី ៧,១% មកត្រឹម ៣,៤% ហើយកំណើន ផសស នៅតៃវ៉ាន់ ថយចុះមកត្រឹម ៤,៩%។

រហូតមកដល់បច្ចុប្បន្ននេះ ប្រទេសសេដ្ឋកិច្ចជឿនលឿនមិនទាន់កសាងឡើងវិញបានទេ នូវទំនុកចិត្តរបស់អ្នកប្រើប្រាស់ និងវិនិយោគិន។ អត្រាកំណើន ផសស ពីមួយឆ្នាំទៅមួយឆ្នាំនៅតំបន់អឺរ៉ូ-១២ ធ្លាក់ចុះមកត្រឹម ១,៦% ដោយសារមួយផ្នែកមកពីផលប៉ះពាល់នៃការរីករវនយោបាយ និងវិបត្តិបំណុលនៅប្រទេសក្រិច។ ដោយមានកំណើន ផសស ពិត ១,៥% ធៀបនឹង ២,៩% នៅត្រីមាសទី២ ឆ្នាំ២០១០ សហរដ្ឋអាមេរិកបន្ដប្រយុទ្ធប្រឆាំងនឹងភាពគ្មានការងារធ្វើ ដែលមានអត្រា ៩,៥% នៅត្រីមាសទី២ ឆ្នាំនេះ។ នៅទីផ្សារ Wall Street ថ្លៃប័ណ្ណភាគហ៊ុនបន្ដឡើងចុះ ដែលឆ្លុះបញ្ចាំងពីនិន្នាការពាណិជ្ជកម្មមិនច្បាស់លាស់។ សេដ្ឋកិច្ចប្រទេសជប៉ុន បន្ដធ្លាក់ចុះ ហើយ ផសស បានរួមចុះ ១,០% ធៀបនឹងកំណើន ៣,៥% កាលពីមួយឆ្នាំមុន ដោយសារ វិបត្តិមិនទាន់ដោះស្រាយបាននៃការសាយភាយវិទ្យុសកម្មក្រោយពេលមានគ្រោះស៊ូណាមិ និងការប៉ះពាល់ដល់ទំនុកចិត្តរបស់អ្នកប្រើប្រាស់ទៅលើផលិតផលជប៉ុន។

## អតិផរណាក្នុងពិភពលោក និងអត្រាប្ដូរប្រាក់

កំណើនថ្លៃ នៅតែជាបញ្ហាមួយសម្រាប់ប្រទេសសេដ្ឋកិច្ចជឿនលឿនភាគច្រើន ទោះបីជាអត្រាកំណើនស្ថិតនៅកម្រិតមួយសមរម្យក៏ដោយ។ នៅត្រីមាសទី២ ឆ្នាំ២០១១ អតិផរណានៅកម្ពុជា ឡើងដល់ ៦,២% ធៀបនឹង ៤,១% កាលពីមួយឆ្នាំមុន។ ទោះបីគេរំពឹងថា អតិផរណានៅប្រទេសកម្ពុជា នឹងនៅថេរក្នុងឆ្នាំនេះ និងឆ្នាំក្រោយ ប៉ុន្ដែអតិផរណាខ្ពស់ដល់ ១៩% នៅប្រទេសវៀតណាម នៅត្រីមាសទី២ ធៀបនឹង ៩% កាលពីមួយឆ្នាំមុន បានបង្កក្ដីបារម្ភដល់កម្ពុជា ដោយសារពាណិជ្ជកម្មទ្វេភាគីរវាងប្រទេសទាំងពីរ កំពុងកើនឡើង។ ការធ្លាក់ថ្លៃដុល្លារអាមេរិក និងការឡើងថ្លៃប្រេង ក៏អាចប៉ះពាល់ដល់អតិផរណានៅកម្ពុជាដែរ។ នៅត្រីមាសទី២ អតិផរណានៅប្រទេសចិនកើនដល់ ៥,៧% ធៀបនឹង ២,៧% កាលពីមួយឆ្នាំមុន។

នៅត្រីមាសទី២ ប្រាក់រៀលឡើងថ្លៃ ៣,៩% ទល់នឹងដុល្លារអាមេរិក បើធៀបនឹងកាលពីមួយឆ្នាំមុន។ ប្រាក់រូពីយ៉ាឥណ្ឌូនេស៊ីឡើងថ្លៃ ៦,០% ដុល្លារសិង្ហបុរី ឡើងថ្លៃ ៨,៨% ប្រាក់យន់ចិនឡើងថ្លៃ ៤,០% និង ដុល្លារតៃវ៉ាន់ ឡើងថ្លៃ ៩,៥%។ ប្រាក់ដុងវៀតណាម ធ្លាក់ថ្លៃ ៨,៩%។

## ថ្លៃផលិតផលនៅទីផ្សារពិភពលោក

នៅត្រីមាសទី២ ផលិតផលសំខាន់ៗបន្ដឡើងថ្លៃ។ ធៀបនឹងមួយឆ្នាំមុន ពោត (US No. 2) ឡើងថ្លៃ ៩៨% ប្រេងឆា (អឺរ៉ុបពាយព្យ) ឡើងថ្លៃ ៤១% និង កៅស៊ូ (SMR 5) ឡើងថ្លៃ ៦១%។ គ្រោះធម្មជាតិនៅបណ្ដាប្រទេសកសិកម្មសំខាន់ៗ ដូចជា ថៃ និង វៀតណាម អាចប៉ះពាល់ដល់ផលស្រូវ និងផលិតផលសំខាន់ៗជាច្រើន។ អង្ករ (Thai 100% B) ឡើងថ្លៃ ១២% ដល់ ៥១៤,៣ដុល្លារក្នុងមួយតោន សណ្ដែកសៀង (US No.1) ឡើងថ្លៃ ៤២% ដល់ ៥២៥,៧ដុល្លារ/តោន។ ក្នុងរយៈពេលដដែល ប្រេងឆៅ (OPEC spot) ឡើងថ្លៃ ៤៧% ដល់ ១១៣,៣ដុល្លារក្នុងមួយធុង ប្រេងសាំង (US Gulf Coast) ឡើងថ្លៃ ៤៥% ដល់ ០,៧៨ដុល្លារក្នុងមួយលីត្រ និង ប្រេងម៉ាស៊ូត (Low sulphur No.2) ឡើងថ្លៃ ៣៧% ដល់ ០,៧៦ដុល្លារក្នុងមួយលីត្រ។

[១] អត្ថបទនេះ រៀបរៀងដោយលោក រ័ត្ន វឌ្ឍនា អ្នកស្រាវជ្រាវនៅវិទ្យាស្ថាន CDRI។

តារាង១. កំណើន ផសស ពិត នៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៤-២០១១ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន)

| | 2004 | 2005 | 2006 | 2007 | 2008 | 2009 | 2010 | | | | 2011 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា | 7.7 | 13.4 | 10.6 | 10.2 | 6.8 | - | - | - | - | - | - | |
| ឥណ្ឌូនេស៊ី | 5.1 | 5.6 | 5.4 | 6.3 | 6.1 | 4.5 | 5.7 | 6.2 | 5.8 | 6.9 | 6.5 | 6.5 |
| ម៉ាឡេស៊ី | 7.0 | 5.2 | 5.9 | 6.3 | 4.6 | -1.7 | 16.9 | 8.9 | 5.3 | 4.8 | 4.6 | 4.0 |
| សិង្ហបុរី | 8.5 | 5.7 | 7.7 | 7.7 | 1.1 | -2.2 | 17.4 | 18.7 | 10.5 | 12.0 | 8.3 | 0.9 |
| ថៃ | 6.0 | 4.5 | 4.8 | 4.9 | 2.6 | -2.3 | 12.0 | 9.2 | 6.7 | 3.8 | 3.0 | 2.6 |
| វៀតណាម | 7.5 | 8.4 | 8.1 | 8.5 | 6.2 | - | 5.8 | 6.4 | 7.2 | 7.3 | 5.4 | 5.7 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន | 9.5 | 9.6 | 10.5 | 11.9 | 9.0 | 8.2 | 11.9 | 10.3 | 9.7 | 9.8 | 9.7 | 9.5 |
| ហុងកុង | 8.3 | 6.5 | 6.6 | 6.4 | 2.4 | -2.8 | 8.0 | 6.5 | 6.8 | 6.2 | 7.2 | 5.1 |
| កូរ៉េខាងត្បូង | 4.7 | 4.7 | 5.0 | 4.9 | 2.2 | 0.0 | 8.1 | 7.1 | 4.5 | 4.8 | 4.2 | 3.4 |
| តៃវ៉ាន់ | 5.7 | 4.1 | 4.6 | 5.2 | 0.1 | -6.3 | 14.6 | 12.9 | 9.8 | 6.9 | 6.5 | 4.9 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ | 1.8 | 1.5 | 2.7 | 2.9 | 0.9 | -3.0 | 0.6 | 1.7 | 1.9 | 2.0 | 2.5 | 1.6 |
| ជប៉ុន | 3.4 | 2.5 | 2.1 | 2.0 | -0.7 | -3.7 | 5.5 | 3.5 | 5.0 | 2.2 | -1.0 | -1.0 |
| សហរដ្ឋអាមេរិក | 4.4 | 3.7 | 3.3 | 2.2 | 1.1 | -2.2 | 2.8 | 2.9 | 2.3 | 2.8 | 2.3 | 1.5 |

*Sources: International Monetary Fund, Economist and countries' statistic offices.*

តារាង២. អត្រាអតិផរណានៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៤-២០១១ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន-មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2004 | 2005 | 2006 | 2007 | 2008 | 2009 | 2010 | | | | 2011 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា | 4.0 | 5.8 | 4.7 | 10.5 | 19.7 | -0.5 | 7.0 | 4.1 | 1.8 | 3.3 | 3.6 | 6.2 |
| ឥណ្ឌូនេស៊ី | 8.3 | 10.5 | 13.4 | 6.4 | 10.1 | 4.9 | 3.6 | 4.4 | 6.2 | 6.3 | 6.8 | 5.9 |
| ម៉ាឡេស៊ី | 1.6 | 3.1 | 3.7 | 2.0 | 5.3 | 0.6 | 1.3 | 1.6 | 1.9 | 2.1 | 2.8 | 3.3 |
| សិង្ហបុរី | 1.7 | 0.5 | 1.0 | 2.1 | 6.5 | 0.2 | 0.9 | 3.1 | 3.4 | 4.0 | 5.2 | 4.7 |
| ថៃ | 2.7 | 4.5 | 4.7 | 2.2 | 5.5 | -0.8 | 3.7 | 3.3 | 3.3 | 2.0 | 3.0 | 4.1 |
| វៀតណាម | 7.8 | 8.2 | 7.7 | 8.3 | 23.3 | 7.1 | 7.5 | 9.0 | 8.4 | 10.9 | 12.8 | 19.4 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន | 3.9 | 1.8 | 1.5 | 4.8 | 5.9 | 0.1 | 2.1 | 2.7 | 3.3 | 4.7 | 5.1 | 5.7 |
| ហុងកុង | -0.4 | 1.1 | 2.2 | 2.0 | 4.3 | 0.5 | 1.9 | 2.6 | 2.3 | 2.9 | 4.0 | 5.1 |
| កូរ៉េខាងត្បូង | 3.5 | 2.8 | 2.4 | 2.5 | 4.6 | 2.8 | 2.7 | 2.6 | 2.9 | 3.6 | 4.4 | 4.2 |
| តៃវ៉ាន់ | 1.6 | 2.3 | 0.6 | 1.8 | 3.2 | -0.7 | 1.3 | 1.1 | 0.4 | 1.1 | 1.3 | 1.6 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ | 2.2 | 2.2 | 2.1 | 2.1 | 3.3 | 0.5 | 1.1 | 1.5 | 1.7 | 2.0 | 2.5 | 2.7 |
| ជប៉ុន | Nil | -0.3 | 0.5 | 0.1 | 1.4 | -1.3 | -1.2 | -0.9 | -0.9 | 0.1 | 0.0 | 0.3 |
| សហរដ្ឋអាមេរិក | 2.7 | 3.4 | 3.2 | 2.9 | 3.8 | -0.3 | 2.3 | 1.8 | 1.2 | 1.3 | 2.1 | 3.5 |

*Sources: International Monetary Fund, Economist and National Institute of Statistics.*

តារាង៣. អត្រាប្តូរប្រាក់ធៀបនឹងដុល្លារអាមេរិកនៃរូបិយវត្ថុរបស់ដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៥-២០១១ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2005 | 2006 | 2007 | 2008 | 2009 | 2010 | | | | 2011 | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | |
| កម្ពុជា (រៀល) | 4092.50 | 4103.20 | 4062.70 | 4054.20 | 4141.03 | 4180.11 | 4209.02 | 4236.69 | 4122.58 | 4041.90 | 4044.89 |
| ឥណ្ឌូនេស៊ី (រូពីយ៉ា) | 9705.00 | 9134.00 | 9419.00 | 9699.00 | 10303.81 | 9266.93 | 9,132.00 | 8995.11 | 8965.70 | 8902.02 | 8593.94 |
| ម៉ាឡេស៊ី (រីងហ្គីត) | 3.80 | 3.70 | 3.30 | 3.30 | 3.50 | 3.37 | 3.24 | 3.15 | 3.11 | 3.05 | 3.02 |
| សិង្ហបុរី (ដុល្លារសិង្ហបុរី) | 1.66 | 1.59 | 1.51 | 4.58 | 1.45 | 1.40 | 1.36 | 1.36 | 1.30 | 1.28 | 1.24 |
| ថៃ (បាត) | 40.20 | 37.90 | 32.22 | 33.36 | 34.13 | 32.90 | 32.33 | 31.63 | 29.99 | 30.56 | 30.28 |
| វៀតណាម (ដុង) | 15,859.00 | 15,994.00 | 16,030.00 | 16,382.00 | 17767.00 | 18,825.67 | 18,993.00 | 19,485.00 | 19499.48 | 20273.83 | 20693.58 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | |
| ចិន (យ៉ាន់) | 8.19 | 7.97 | 8.03 | 6.94 | 6.83 | 6.83 | 6.77 | 6.77 | 6.66 | 6.58 | 6.50 |
| ហុងកុង (ដុល្លារហុងកុង) | 7.78 | 7.77 | 7.80 | 7.78 | 7.75 | 7.76 | 7.78 | 7.77 | 7.76 | 7.79 | 7.78 |
| កូរ៉េខាងត្បូង (វ៉ុន) | 1024.00 | 955.00 | 929.04 | 1137.23 | 1273.30 | 1143.97 | 1166.04 | 1182.41 | 1132.85 | 1120.19 | 1084.27 |
| តៃវ៉ាន់ (ដុល្លារតៃវ៉ាន់-NT$) | 32.10 | 32.50 | 32.85 | 31.54 | 33.04 | 31.93 | 31.90 | 31.90 | 30.36 | 29.30 | 28.86 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | |
| អឺរ៉ូ-១២ (អឺរ៉ូ) | 0.80 | 0.80 | 0.70 | 0.84 | 0.71 | 0.72 | 0.79 | 0.77 | 0.74 | 0.73 | 0.70 |
| ជប៉ុន (យ៉េន) | 110.20 | 116.40 | 117.80 | 102.46 | 93.26 | 90.73 | 92.20 | 85.74 | 82.53 | 82.33 | 81.66 |

*Sources: International Monetary Fund, Economist and National Bank of Cambodia*

តារាង៤. ថ្លៃផលិតផលជ្រើសរើសនៅលើទីផ្សារពិភពលោក ពីឆ្នាំ២០០៥-២០១១ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2005 | 2006 | 2007 | 2008 | 2009 | 2010 | | | | 2011 | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| ពោត (US No. 2) - USA (USD/តោន) | 110.65 | 111.04 | 149.08 | 218.15 | 167.32 | 162.88 | 157.41 | 176.13 | 238.81 | 280.32 | 311.63 |
| ប្រេងឆា-អឺរ៉ុបពាយព្យ (USD/តោន) | 427.47 | 433.85 | 707.68 | 912.23 | 686.84 | 807.67 | 813.00 | 874.67 | 1108.00 | 1251.00 | 1147.00 |
| កៅស៊ូ SMR 5 | 1430.5 | 1996.30 | 2202.30 | 2586.30 | 1890.5 | 3105.90 | 3083.73 | 3175.97 | 4257.27 | 5278.03 | 4968.77 |
| អង្ករ (Thai 100%B) - បាងកក (USD/តោន) | 221.67 | 282.00 | 305.36 | 615.32 | 474.47 | 565.67 | 461.33 | 468.33 | 531.00 | 528.25 | 514.33 |
| សណ្តែកសៀង (US No. 1) - USA (USD/តោន) | 262.03 | 213.88 | 294.59 | 460.41 | 444.25 | 372.68 | 370.95 | 406.88 | 480.24 | 537.24 | 525.66 |
| ប្រេងឆៅ - OPEC spot (USD/ធុង) | 33.50 | 61.58 | 69.25 | 95.44 | 237.26 | 75.73 | 77.00 | 74.91 | 84.17 | 100.70 | 113.31 |
| សាំង - US Gulf Coast (សេន/លីត្រ) | 30.90 | 47.70 | 53.58 | 62.22 | 51.70 | 53.87 | 54.43 | 51.54 | 57.23 | 67.92 | 78.73 |
| ម៉ាស៊ូត (ស្ពាន់ធ័រតិច លេខ២) - US Gulf Coast (សេន/លីត្រ) | 29.48 | 51.35 | 55.51 | 76.20 | 42.98 | 53.87 | 55.13 | 53.64 | 61.68 | 72.47 | 75.72 |

*Sources: Food and Agriculture Organisation and US Energy Information Administration*

# តាមដានសេដ្ឋកិច្ច-ស្ថានភាពក្នុងប្រទេស[១]

## សកម្មភាពសេដ្ឋកិច្ចចំបងៗ

វិស័យសេវាកម្ម នៅតែជាកត្តាជំរុញចំបងមួយនៃការងើបសេដ្ឋកិច្ចឡើងវិញនៅកម្ពុជា។ នៅត្រីមាសទី២ គម្រោងវិនិយោគឯកជនក្នុងវិស័យសេវាកម្ម អនុម័តដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានចំនួន ២២២៩,២លានដុល្លារ គឺកើនឡើង ៩៦៤% ធៀបនឹងត្រីមាសមុន ឬកើន ១៧៣៣% ធៀបនឹងឆ្នាំមុន។ វិស័យនេះបានកើនឡើង ទោះបីជាមានការធ្លាក់ចុះចំនួនភ្ញៀវបរទេសមកដល់តាមផ្លូវអាកាស (៣៣%) និងតាមផ្លូវគោក និងផ្លូវទឹក (៩%) នៅត្រីមាសទី២ នេះ បើធៀបនឹងត្រីមាសមុនក្តី។ វិស័យឧស្សាហកម្ម ជាពិសេសវិស័យកាត់ដេរ ក៏បង្ហាញសញ្ញានៃការងើបឡើងវិញដែរ ដោយកើន ៥១៦% ធៀបនឹងត្រីមាសមុន ឬ ៦៥៩% ធៀបនឹងមួយឆ្នាំមុនដល់ ៤១៣,៥លានដុល្លារ។ ប៉ុន្តែចំណែកនៃវិស័យកាត់ដេរ ធ្លាក់ចុះដល់ ២៦% ធៀបនឹង ៨៥% នៅត្រីមាសទី១ និង ៣៩% កាលពីមួយឆ្នាំមុន ដែលអាចបង្ហាញពីពិពិធកម្មនៃវិស័យឧស្សាហកម្ម។

ទោះបីប្រទេសចិន និងប្រទេសអាស៊ាននានា បានចាប់អារម្មណ៍កាន់តែខ្លាំងលើវិនិយោគក្នុងផ្នែកស្រូវអង្ករ និងផ្នែកកសិកម្មផ្សេងៗទៀតក្តី ក៏កម្ពុជានៅតែពិបាកទាក់ទាញបាននូវវិនិយោគក្នុងស្រុក និងបរទេស។ នៅត្រីមាសទី២ នេះ មិនមានការអនុម័តគម្រោងវិនិយោគកសិកម្មថ្មី ឬពង្រីកបន្ថែមទេ។ វិស័យសំណង់ បន្តងើបឡើងវិញ ដោយសារគម្រោងសាងសង់ដែលបានផ្អាក ដូចជា Vattanac Tower បានចាប់ដំណើរការឡើងវិញ។ តម្លៃគម្រោងសំណង់ភូមិគ្រឹះនិងផ្ទះ និងផ្ទះល្វែង បានអនុម័តកើន ៧៧% ដល់ ៧៧,៤លានដុល្លារ ធៀបនឹងត្រីមាសមុន ប៉ុន្តែនៅទាបជាខ្លាំង បើធៀបនឹងមុនពេលមានវិបត្តិ។

នៅត្រីមាសទី២ ការនាំចេញបន្តស្ទុះឡើង ដល់ ១១៣២,១ លានដុល្លារ ឬ កើន ៣៨% ធៀបនឹងឆ្នាំមុន ដោយក្នុងនេះផលិតផលកាត់ដេរ រួមចំណែកបាន ៨៥% និងផ្តោតជាសំខាន់លើទីផ្សារសហភាពអឺរ៉ុប និងសហរដ្ឋអាមេរិក។ ប៉ុន្តែកំណើនពីមួយឆ្នាំទៅមួយឆ្នាំ នៃការនាំចេញផលិតផលកាត់ដេរ ទៅសហរដ្ឋអាមេរិក (១២%) និងសហភាពអឺរ៉ុប (៦៣%) មានកម្រិតទាបជាងទៅតំបន់អាស៊ាន (១២១,១%) ជប៉ុន (៨៨%) និងប្រទេសផ្សេងៗទៀត (៦៦%)។ ក្នុងរយៈពេលដដែល ការនាំចេញផលិតផលកសិកម្មកើន ៥១៧% ដល់ ១៦៨ លានដុល្លារ ការនាំចេញកៅស៊ូកើន ២៥២% ដល់ ៤៨,៦ លានដុល្លារ និងការនាំចេញឈើកើន ២៧៣% ដល់ ១៦,៨ លានដុល្លារ។ ប៉ុន្តែការនាំចេញត្រីធ្លាក់ចុះ ៤៣% មកត្រឹម ០,៤លានដុល្លារ។

ក្នុងរយៈពេលដដែល ការនាំចូលសរុបកើន ៦៣% ដល់ ៩១៨,៨លានដុល្លារ ក្នុងនេះការនាំចូលប្រេងសាំងមានចំណែក ៨,៣% និង ការនាំចូលប្រេងម៉ាស៊ូតមាន ១៥%។ ការនាំចូលប្រេងសាំងកើន ២៤២% និងការនាំចូលប្រេងម៉ាស៊ូតកើន ១៣៤%។ ការនាំចូលសម្ភារៈសំណង់ ធ្លាក់ចុះ ៤,០% មកត្រឹម ១២,៧លានដុល្លារ ដោយសារកំណើនយឺតនៃវិស័យអចលនទ្រព្យ។

## ហិរញ្ញវត្ថុសាធារណៈ

នៅត្រីមាសទី៤ឆ្នាំ២០១០ចំណូលសរុបរបស់រាជរដ្ឋាភិបាលកើន ១៧% ដល់ ១៦៧៥ពាន់លានរៀល ធៀបនឹងត្រីមាសទី៣ ក្នុងនោះមាន ៩៤% ជាចំណូលចរន្ត។ ចំណូលពន្ធកើន ០,៣% ដល់ ១២២៩,៦ពាន់លានរៀល ស្របពេលដែលចំណូលមិនមែនពន្ធ កើន ៦៦% ដល់ ៣៤០,៩ពាន់លានរៀល។ ក្នុងរយៈពេលដដែល ចំណាយសរុបថយចុះ ១៩% មកត្រឹម ១៩៤៥,៤ពាន់លានរៀល ក្នុងនោះចំណាយមូលធនធ្លាក់ចុះ ២៤% មកត្រឹម ៦៧៥,៦ពាន់លានរៀល ហើយចំណាយចរន្តធ្លាក់ចុះ ១៦% មកត្រឹម ១២៦៩,៨ពាន់លានរៀល។ នៅត្រីមាស ទី៤ ចំណាយលើប្រាក់បៀវត្សរ៍សរុប មានចំណែក ៤៥% នៃចំណាយចរន្ត ខណៈដែលឧបត្ថម្ភធន និងជំនួយសង្គមកិច្ច មានចំណែក ១៨%។ ឱនភាពថវិកា មានសរុប ២០៧,៣ពាន់លានរៀល។

## អតិផរណា និងអត្រាប្តូរប្រាក់បរទេស

ការគ្រប់គ្រងអតិផរណា នៅតែមានបញ្ហា។ នៅត្រីមាសទី២ ឆ្នាំ២០១១ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (គ្រប់មុខ) កើន ៦,៣% ធៀបនឹងមួយឆ្នាំមុន។ ថ្លៃអាហារ និងភេសជ្ជៈគ្មានជាតិស្រាកើន ៧,៦% ប៉ុន្តែថ្លៃដឹកជញ្ជូន ធ្លាក់ចុះ ៧,៣%។ ក្នុងរយៈពេលដដែល មាសឡើងថ្លៃ ២៧% ដល់ ១៨១,៥ដុល្លារ/ជីប្រេងម៉ាស៊ូតឡើងថ្លៃ ២៥% ដល់ ៤៧៨៤,៦រៀល/លីត្រ និងប្រេងសាំងឡើងថ្លៃ ១៦% ដល់ ៥០៦៥,៥រៀល/លីត្រ។ ប្រាក់រៀលឡើងថ្លៃ ៣,៨% ធៀបនឹងប្រាក់ដុល្លារអាមេរិក ដល់ ៤០៤៤,៩រៀល/ដុល្លារ និង ១១% ធៀបនឹងប្រាក់ដុងវៀតណាម ដល់ ១៩,៦រៀល/១០០ដុង ប៉ុន្តែ ធ្លាក់ថ្លៃ ៣% ទល់នឹងប្រាក់បាតថៃ ដោយប្តូរបាន ១៣៣,៨រៀល/បាត។

## ការវិវត្តរូបិយវត្ថុ

នៅត្រីមាសទី១ ឆ្នាំ២០១១ រូបិយវត្ថុទូទៅ (M2) កើន ១៧,៦% ធៀបនឹងមួយឆ្នាំមុន ដល់ ២០.២៧៨,៣ពាន់លានរៀល ដោយក្នុងនោះ ទ្រព្យសកម្មបរទេសសុទ្ធ កើន ១០,១% ដល់ ១៧.០៧៩ពាន់លានរៀល ហើយទ្រព្យសកម្មក្នុងស្រុកសុទ្ធកើន ៨៦% ដល់ ៣១៩៩,២ពាន់លានរៀល។ ក្នុងរយៈពេលដដែល រូបិយវត្ថុ M1 កើន ១១,១% ដល់ ៣៤៩៧,២ពាន់លានរៀល និងរូបិយវត្ថុផ្សេងៗ កើន ១៩,១% ដល់ ១៦.៧៨១,១ពាន់លានរៀល។

## ស្ថានភាពក្រីក្រ

យោងតាមអង្កេតពលករងាយរងគ្រោះរបស់ CDRI ក្នុងខែសីហា ប្រាក់ចំណូលប្រចាំថ្ងៃពិតរបស់ពលករ ២ក្រុម ក្នុងចំណោម ៩ក្រុមមិនមែនខាងកាត់ដេរ បានធ្លាក់ចុះ។ អ្នកបម្រើតុ

១ អត្ថបទនេះ រៀបរៀងដោយលោក វ័ត្ន វឌ្ឍនា អ្នកស្រាវជ្រាវ កញ្ញា អ៊ួន វិមល និង លោកស្រី ប៉ុន ដូរីណា ជាជំនួយការស្រាវជ្រាវនៅវិទ្យាស្ថាន CDRI។

តាមភោជនីយដ្ឋាន រងគ្រោះខ្លាំងបំផុត ដោយសារប្រាក់ចំណូលប្រចាំថ្ងៃពិតធ្លាក់ចុះ១៦%បន្ទាប់មកគឺអ្នកលីសែង(ចុះ០,៦%)។ ប្រាក់ចំណូលប្រចាំថ្ងៃពិត កើនឡើងសម្រាប់កម្មករសំណង់មានជំនាញ អ្នកលក់បន្លែតូចតាច អ្នកស៊ីឈ្នួលធ្វើស្រែ អ្នករត់ម៉ូតូឌុប អ្នកធាក់ស៊ីក្លូ អ្នករើសអេតចាយ និងកម្មករសំណង់គ្មានជំនាញ។

ដូចមានបង្ហាញក្នុងតារាង៨ អ្នកបម្រើតុតាមភោជនីយដ្ឋាន រងគ្រោះខ្លាំងបំផុត ដោយប្រាក់ចំណូលប្រចាំថ្ងៃពិត ធ្លាក់ចុះ ១៦% មកត្រឹម ៥៤១០រៀល ធៀបនឹង ៦៤២៧រៀល កាលពីខែដូចគ្នា ឆ្នាំ២០១០ ប៉ុន្តែចំណាយប្រចាំថ្ងៃ ក៏ធ្លាក់ចុះ ២,៦% មកត្រឹម ១៤០២,៤រៀលដែរ។ ទោះបីជាប្រាក់ចំណូលធ្លាក់ចុះគួរឱ្យកត់សម្គាល់ដូច្នេះក្តី ក៏មានអ្នកបម្រើតុតែ ១២% ប៉ុណ្ណោះដែលជំពាក់បំណុលគេ។

ក្នុងចំណោមក្រុមពលកមិនមែនខាងកាត់ដេរទាំង ៩ក្រុម ប្រាក់ចំណូលរបស់អ្នកលីសែង បានធ្លាក់ចុះបន្តិច ពី ១០.៥២៥រៀល មកត្រឹម ១០.៤៦៥រៀល ហើយចំណាយប្រចាំថ្ងៃរបស់ពួកគេ កើន ០,៨% ដល់ ៥៦០៥រៀល។ ក្នុងចំណោមអ្នកលីសែងបានឆ្លើយសម្ភាសន៍ មាន ៧៥% ត្រូវជួលកន្លែងស្នាក់នៅ ២២,៥% ស្នាក់នៅផ្ទះបងប្អូន និង ២,៥% រស់នៅតាមដងផ្លូវ ឬនៅវត្ត។

ប្រាក់ចំណូលប្រចាំថ្ងៃរបស់កម្មករសំណង់គ្មានជំនាញ ស្ទុះឡើង ២០% ទៀត (ពីមុនបាន ៨៧៤៤រៀល) ដោយសារអនុម័តគម្រោងសាងសង់មានច្រើន ដោយកើនចំនួនដល់ ២៧៨% ចាប់ពីខែសីហា ២០១០ ដល់ខែសីហា ២០១១។ អង្កេតបានរកឃើញថា កម្មករសំណង់គ្មានជំនាញ ៦០% បានរៀបការរួច ៣៧,៥% នៅលីវ និង ២,៥% ជាពោះម៉ាយ ឬមេម៉ាយ។

ប្រាក់ចំណូលរបស់អ្នកស៊ីឈ្នួលធ្វើស្រែ មានកំណើនខ្ពស់បំផុតលំដាប់ទី២ គឺកើនជិតដល់ ១៩% ពី ៦១៨៦រៀល ដល់ ៧៣៤៥រៀល ថ្វីបើវាបានធ្លាក់ចុះកាលពីដើមឆ្នាំក្តី។ អ្នកស៊ីឈ្នួលធ្វើស្រែ ៥៥% គ្មានដីធ្វើស្រែទេ ខណៈដែល ៤០% មានដីកសិកម្ម តិចជាង ១ហិកតា។

ប្រាក់ចំណូលប្រចាំថ្ងៃពិតរបស់អ្នករើសអេតចាយកើន១៧% ដល់ ៧៥៥៧រៀល ធៀបនឹងខែដូចគ្នាឆ្នាំមុន ដោយសាររបស់អេតចាយឡើងថ្លៃ។ ក្នុងចំណោមអ្នករើសអេតចាយបានឆ្លើយសម្ភាសន៍ មាន ៤២,៥% បានចូលរៀនបឋមសិក្សា ១២,៥% ចូលរៀនអនុវិទ្យាល័យ ២,៥% ចូលរៀនវិទ្យាល័យ និង ៤២,៥% មិនបានចូលរៀនទេ។

ប្រាក់ចំណូលរបស់អ្នកធាក់ស៊ីក្លូ ដែលធ្លាក់ចុះកាលពីខែឧសភា បានកើនឡើងវិញនៅខែសីហា។ អ្នកធាក់ស៊ីក្លូបានឆ្លើយសម្ភាសន៍ទាំងអស់ សុទ្ធតែជាអ្នករកចំណូលចម្បងចិញ្ចឹមគ្រួសារ។

ចំណូលប្រចាំថ្ងៃពិតរបស់កម្មករកាត់ដេរ កើនឡើង ២,៦% ដល់ ៨៦៨៧រៀល/ថ្ងៃ ធៀបនឹង ៨៤៧០រៀល/ថ្ងៃ កាលពីខែសីហា ឆ្នាំមុន។ មាន ២៧% នៃកម្មករកាត់ដេរ ឆ្លើយសម្ភាសន៍ទាំងអស់ បានធ្វើការម៉ោងបន្ថែមញឹកញាប់ ៥៨% បានធ្វើការម៉ោងបន្ថែមខ្លះៗ និង ១៥% មិនបានធ្វើការម៉ោងបន្ថែមទេ។

តារាង១. គម្រោងវិនិយោគឯកជនបានអនុម័ត ឆ្នាំ២០០៤-១១

| | 2004 | 2005 | 2006 | 2007 | 2008 | 2009 | 2010 | | | | 2011 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| | ទ្រព្យសកម្មជាប់លាប់ (លានដុល្លារ) | | | | | | | | | | | |
| កសិកម្ម | 12.3 | 26.8 | 498.0 | 135.6 | 92 | 445.8 | 165.7 | 41.4 | 278.0 | 36.7 | 4.1 | 0.0 |
| ឧស្សាហកម្ម | 187.9 | 914.6 | 365.3 | 709.1 | 724.9 | 1043.3 | 247.7 | 54.5 | 44.3 | 87.7 | 67.1 | 413.5 |
| *កាត់ដេរ* | *132.6* | *174.4* | *89.4* | *170.7* | *142.8* | *87.58* | *13.1* | *21.3* | *29.3* | *50.0* | *57.1* | *108.4* |
| សេវាកម្ម | 91.8 | 155.5 | 2939.1 | 1742.5 | 10,003.2 | 4121.5 | 89.5 | 121.6 | 0 | 1096.2 | 209.5 | 2229.2 |
| *សណ្ឋាគារ និងទេសចរណ៍* | *55.9* | *102.6* | *345.0* | *1048.3* | *8758.1* | *3980.1* | *3.78* | *14.0* | *0* | *1087.4* | *107.9* | *2221.9* |
| សរុប | 292.0 | 1096.9 | 3802.4 | 2587.2 | 10570.9 | 5610.6 | 502.9 | 217.5 | 322.3 | 1220.6 | 280.72 | 2642.7 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | - | -91.2 | -56.8 | 48.2 | 278.8 | -77.0 | 841.4 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | -5.6 | 275.6 | 246.6 | -32.0 | 308.6 | -46.9 | -59.8 | 452.0 | -16.6 | -71.3 | -44.2 | 1115.0 |

*Including expansion project approvals. Source: Cambodian Investment Board*

តារាង២. តម្លៃគម្រោងសំណង់នៅភ្នំពេញបានអនុម័ត ឆ្នាំ២០០៤-១១

| | 2004 | 2005 | 2006 | 2007 | 2008 | 2009 | 2010 | | | | 2011 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| | លានដុល្លារ | | | | | | | | | | | |
| ភូមិគ្រឹះ និងផ្ទះ | 30.3 | 45.5 | 33.1 | 79.1 | 154.7 | 64.3 | 5.1 | 7.5 | 14.1 | 9.5 | 4.1 | 5.9 |
| ផ្ទះល្វែង | 167.6 | 204.2 | 213.3 | 297.2 | 221.6 | 149.6 | 11.1 | 127.2 | 25.3 | 20.3 | 16.1 | 22.8 |
| ផ្សេងៗ | 65.6 | 109.1 | 76.8 | 259.6 | 740.9 | 187.8 | 35.2 | 67.4 | 38.9 | 76.2 | 23.6 | 48.7 |
| សរុប | 263.5 | 358.8 | 323.3 | 635.8 | 1117.0 | 401.7 | 51.4 | 202.1 | 78.4 | 106.0 | 43.8 | 77.4 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | - | -23.1 | 293.2 | -61.2 | 35.3 | -58.7 | 76.7 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | 32.5 | 36.2 | -9.9 | 96.7 | 75.7 | -64.0 | -71.6 | 224.4 | -14.2 | 58.7 | -14.8 | -61.7 |

*Source: Department of Cadastre and Geography of Phnom Penh municipality*

## តារាង៣. ចំនួនអ្នកដំណើរមកដល់ប្រទេសកម្ពុជា ឆ្នាំ២០០៤-១១

| | 2004 | 2005 | 2006 | 2007 | 2008 | 2009 | 2010 | | | | 2011 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| | ចំនួនអ្នកដំណើរ (ពាន់នាក់) | | | | | | | | | | | |
| តាមផ្លូវអាកាស | 626.1 | 856.5 | 1029.0 | 1296.5 | 1239.4 | 1111.7 | 371.5 | 260.9 | 288.3 | 383.7 | 427.4 | 286.9 |
| តាមផ្លូវគោក និងទឹក | 428.9 | 565.1 | 672.9 | 718.6 | 881.9 | 1049.8 | 312.2 | 276.6 | 293.8 | 321.4 | 351.0 | 319.6 |
| សរុប | 1055.0 | 1421.6 | 1701.9 | 2015.1 | 2121.3 | 2161.5 | 683.7 | 537.5 | 582.0 | 705.1 | 778.4 | 606.5 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | - | 16.4 | -21.4 | 8.3 | 21.2 | 10.4 | -22.1 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | 50.5 | 34.7 | 19.7 | 28.4 | 5.3 | 1.9 | 9.9 | 15.8 | 19.4 | 20.0 | 13.9 | 12.8 |

*Source: Ministry of Tourism*

## តារាង៤. ការនាំចេញ និងនាំចូល ឆ្នាំ២០០៤-១១

| | 2004 | 2005 | 2006 | 2007 | 2008 | 2009 | 2010 | | | | 2011 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| | លានដុល្លារ | | | | | | | | | | | |
| ការនាំចេញសរុប | 2099.4 | 2452.4 | 2922.8 | 3161.6 | 3209.5 | 2889.0 | 693.8 | 820.8 | 1045.4 | 1070.9 | 1017.6 | 1132.1 |
| ក្នុងនេះ៖ សម្លៀកបំពាក់* | 2027.0 | 2352.8 | 2810.8 | 3050.2 | 3097.8 | 2565.3 | 625.5 | 716.9 | 938.3 | 942.7 | 880.5 | 964.2 |
| *- សហរដ្ឋអាមេរិក* | 1270.9 | 1555.6 | 1851.7 | 1959.9 | 1913.0 | 1512.6 | 380.5 | 416.7 | 531.9 | 524.8 | 464.5 | 466.7 |
| *- សហភាពអឺរ៉ុប* | 590.8 | 506.9 | 603.0 | 660.9 | 693.4 | 644.7 | 137.2 | 184.8 | 239.4 | 248.0 | 232.0 | 301.4 |
| *- អាស៊ាន* | 1.7 | 70.7 | 80.4 | 90.3 | 99.6 | 6.9 | 2.2 | 1.9 | 2.9 | 3.0 | 3.8 | 4.2 |
| *- ជប៉ុន* | 22.1 | 25.0 | 40.6 | 30.1 | 26.5 | 44.6 | 19.8 | 14.9 | 25.5 | 26.3 | 34.3 | 28.0 |
| *- ប្រទេសផ្សេងៗ* | 141.5 | 194.6 | 235.1 | 309.0 | 365.3 | 356.5 | 85.7 | 98.6 | 138.6 | 140.7 | 145.9 | 163.9 |
| កសិកម្ម | 53.5 | 61.3 | 59.7 | 55.6 | 44.6 | 60.5 | 21.2 | 27.2 | 44.9 | 72.3 | 74.0 | 167.9 |
| *- កៅស៊ូ* | 30.2 | 36.7 | 41.5 | 41.0 | 35.8 | 39.8 | 11.9 | 13.8 | 25.4 | 38.1 | 49.9 | 48.6 |
| *- ឈើ* | 11.1 | 10.3 | 8.6 | 8.7 | 3.4 | 3.5 | 2.8 | 4.5 | 8.8 | 18.7 | 6.2 | 16.8 |
| *- ត្រី* | 9.8 | 10.1 | 5.9 | 3.2 | 2.3 | 3.2 | 0.8 | 0.7 | 0.5 | 0.8 | 0.6 | 0.4 |
| *- ផ្សេងៗ* | 2.4 | 4.2 | 3.7 | 2.7 | 3.1 | 14.0 | 5.7 | 8.2 | 10.2 | 14.7 | 17.3 | 31.3 |
| ផ្សេងៗ | 18.9 | 38.3 | 52.3 | 55.8 | 67.1 | 263.2 | 47.1 | 76.7 | 62.2 | 55.9 | 63.2 | 70.8 |
| ការនាំចូលសរុប | 871.1 | 2513.0 | 512.2 | 554.8 | 1010.9 | 2239.0 | 505.6 | 563.2 | 731.3 | 677.1 | 728.7 | 918.8 |
| ក្នុងនេះ៖ សាំង | 30.2 | 40.2 | 38.8 | 58.7 | 70.1 | 91.2 | 28.8 | 22.4 | 27.6 | 30.5 | 62.0 | 76.7 |
| ម៉ាស៊ូត | 109.4 | 93.1 | 113.0 | 122.8 | 113.5 | 180.8 | 49.8 | 55.4 | 48.0 | 50.5 | 92.5 | 129.8 |
| សម្ភារៈសំណង់ | 23.2 | 134.7 | 56.5 | 69.0 | 77.8 | 49.7 | 13.7 | 13.2 | 16.7 | 13.8 | 11.8 | 12.7 |
| ផ្សេងៗ | 708.4 | 2245.0 | 303.9 | 304.3 | 749.5 | 1917.3 | 413.3 | 472.2 | 638.9 | 582.3 | 562.4 | 699.6 |
| ជញ្ជីងពាណិជ្ជកម្ម | 1228.3 | -60.6 | 2410.6 | 2606.8 | 2198.6 | 650.0 | 188.2 | 257.6 | 314.1 | 393.8 | 289.0 | 213.3 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| ការនាំចេញសម្លៀកបំពាក់សរុប | - | - | - | - | - | - | 8.0 | 14.6 | 30.9 | 0.5 | -6.6 | 9.5 |
| ការនាំចេញសរុប | - | - | - | - | - | - | 5.9 | 18.3 | 27.3 | 2.4 | -5.0 | 11.3 |
| ការនាំចូលសរុប | - | - | - | - | - | - | -5.1 | 11.4 | 29.8 | -7.4 | 7.6 | 26.1 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| ការនាំចេញសម្លៀកបំពាក់សរុប | 24.5 | 16.1 | 19.5 | 8.5 | 1.6 | -10.0 | 4.0 | 45.6 | 75.2 | 62.7 | 40.8 | 34.5 |
| ការនាំចេញសរុប | 23.4 | 16.3 | 19.2 | 8.2 | 1.5 | -17.2 | -2.3 | 46.8 | 68.5 | 63.5 | 46.7 | 37.9 |
| ការនាំចូលសរុប | 13.2 | 189.6 | -79.6 | 8.3 | 82.2 | 121.5 | -14.5 | -7.4 | 51.0 | 27.1 | 44.1 | 63.1 |

*Import data include tax-exempt imports. Sources: Department of Trade Preferences Systems, MOC and Customs and Excise Department, MEF (website).*

## តារាង៥. ប្រតិបត្តិការថវិកាជាតិលើមូលដ្ឋានសាច់ប្រាក់ ឆ្នាំ២០០៥-១១ (ពាន់លានរៀល)

| | 2005 | 2006 | 2007 | 2008 | 2009 | | | | 2010 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| ចំណូលសរុប | 2625.0 | 3259.2 | 1146.1 | 5290.0 | 1101.7 | 1252.7 | 1184.7 | 1346.1 | 1536.8 | 1341.1 | 1436.0 | 1675.0 |
| ចំណូលចរន្ត | 2474.0 | 2881.8 | 1141.6 | 5210.7 | 1097.7 | 1245.7 | 1174.9 | 1337.7 | 1526.4 | 1330.9 | 1431.2 | 1570.5 |
| ចំណូលពន្ធ | 1911.0 | 2270.9 | 965.2 | 4409.9 | 947.4 | 1096.5 | 999.5 | 1224.1 | 1094.1 | 1143.8 | 1225.5 | 1229.6 |
| ពន្ធក្នុងស្រុក | - | - | 661.8 | 3248.4 | 712.0 | 838.7 | 731.8 | 808.5 | 820.3 | 890.9 | 916.9 | 905.5 |
| ពន្ធលើពាណិជ្ជកម្មក្រៅប្រទេស | - | - | 303.5 | 1161.5 | 235.4 | 257.8 | 268.0 | 303.4 | 273.7 | 253.0 | 308.6 | 324.1 |
| ចំណូលមិនមែនពន្ធ | 563.0 | 610.9 | 176.4 | 800.8 | 150.3 | 149.2 | 176.1 | 225.7 | 432.4 | 187.1 | 205.7 | 340.9 |
| ចំណូលលើទ្រព្យសម្បត្តិ | - | - | 13.6 | 78.0 | 13.1 | 9.7 | 27.5 | 14.3 | 237.0 | 20.2 | 19.5 | 14.5 |
| លក់ទំនិញ និងសេវា | - | - | 124.3 | 424.7 | 93.5 | 100.9 | 91.7 | 121.9 | 108.4 | 102.9 | 127.0 | 121.7 |
| ចំណូលមិនមែនពន្ធផ្សេងទៀត | - | - | 38.5 | 298.2 | 43.7 | 38.6 | 56.5 | 89.5 | 84.0 | 61.0 | 59.2 | 204.8 |
| ចំណូលជាមូលធន | 152.0 | 377.4 | 4.5 | 79.3 | 4.0 | 7.0 | 9.8 | 8.4 | 10.4 | 10.2 | 4.8 | 104.5 |
| ចំណាយសរុប | 3295.0 | 4174.7 | 1689.7 | 6297.8 | 1650.6 | 1766.1 | 2089.5 | 1877.1 | 2129.4 | 2154.8 | 2390.3 | 1945.4 |
| ចំណាយជាមូលធន | 1328.0 | 1638.1 | 807.4 | 2574.4 | 693.6 | 607.1 | 759.2 | 634.9 | - | 913.0 | 887.0 | 675.6 |
| ចំណាយចរន្ត | 1967.0 | 2536.8 | 882.3 | 3809.0 | 752.4 | 1064.7 | 1290.4 | 1332.3 | 831.8 | 1168.1 | 1503.3 | 1269.8 |
| បៀវត្សរ៍ | 711.0 | 822.0 | 362.6 | 1397.0 | 327.4 | 515.5 | 526.6 | 642.5 | - | 545.6 | 562.4 | 567.4 |
| ឧបត្ថម្ភធន និងជំនួយសង្គមកិច្ច | - | - | 194.2 | 927.1 | 217.3 | 185.9 | 272.6 | 195.6 | 213.3 | 253.2 | 401.5 | 231.4 |
| ចំណាយចរន្តផ្សេងទៀត | - | - | 325.5 | 1384.9 | 207.7 | 363.2 | 491.2 | 494.3 | 449.6 | 369.3 | 539.4 | 471.0 |
| សមតុល្យជាទូទៅ | -706.0 | -915.6 | -543.6 | -1007.8 | -548.9 | -513.4 | -904.8 | 90.2 | -592.6 | -813.7 | -954.2 | -207.3 |
| ហិរញ្ញប្បទានពីក្រៅប្រទេស | 1127.0 | 1360.7 | 741.5 | 2055.1 | 507.8 | 326.7 | 484.5 | -531.0 | 270.8 | 746.0 | 409.1 | 419.3 |
| ហិរញ្ញប្បទានក្នុងស្រុក | -396.0 | -445.1 | -185.8 | -127 | -310.3 | 236.5 | 316.4 | 406.4 | 422.8 | 194.1 | 343.3 | -21.6 |

*Source: MEF website.*

## តារាង៦. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ អត្រាប្តូរប្រាក់ និងថ្លៃមាស (មធ្យមភាគតាមការិយបរិច្ឆេទ) ២០០៤-១០

| | 2004 | 2005 | 2006 | 2007 | 2008 | 2009 | 2010 | | | | 2011 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| (តុលា-ធ្នូ ២០០៦:១០០) | សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន) | | | | | | | | | | | |
| ភ្នំពេញ - ទំនិញគ្រប់មុខ | 3.9 | 5.8 | 4.7 | 5.8 | 19.7 | -0.7 | 7.0 | 4.1 | 1.8 | 3.3 | 3.6 | 6.3 |
| - ស្បៀងអាហារ និងភេសជ្ជៈគ្មានជាតិស្រា | 6.4 | 8.6 | 6.4 | 9.9 | 33.1 | -0.3 | 7.8 | 3.6 | 1.9 | 4.1 | 3.9 | 7.6 |
| - ដឹកជញ្ជូន | 9.7 | 11.4 | 9.1 | 5.8 | 19.4 | -10.7 | 12.9 | 8.7 | 3.2 | 3.1 | 5.0 | 7.3 |
| | អត្រាប្តូរប្រាក់ ថ្លៃមាស ថ្លៃប្រេងឥន្ធនៈ (តាមអត្រាទីផ្សារនៅភ្នំពេញ) | | | | | | | | | | | |
| រៀលក្នុង ១ ដុល្លារ | 4016.3 | 4119.7 | 4119.0 | 4062.7 | 4058.2 | 4140.5 | 4180.1 | 4209.0 | 4236.7 | 4122.6 | 4041.9 | 4044.9 |
| រៀលក្នុង ១ បាតថៃ | 99.9 | 102.6 | 108.7 | 122.8 | 123.5 | 121.2 | 127.0 | 129.9 | 138.3 | 137.3 | 132.7 | 133.8 |
| រៀលក្នុង ១០០ ដុងវៀតណាម | 25.5 | 25.8 | 25.1 | 25.0 | 24.8 | 23.4 | 22.3 | 22.1 | 21.4 | 21.1 | 19.9 | 19.6 |
| ថ្លៃមាស (ដុល្លារក្នុង១ជី) | 46.3 | 54.0 | 70.6 | 83.2 | 105.9 | 118.3 | 133.9 | 142.9 | 147.8 | 165.7 | 147.9 | 181.5 |
| ថ្លៃម៉ាស៊ូត (រៀល/លីត្រ) | 2088.0 | 2633.0 | 3140.0 | 3262.3 | 4555.2 | 3294.9 | 3599.5 | 3835.1 | 3936.6 | 4066.1 | 4427.2 | 4784.6 |
| ថ្លៃសាំង (រៀល/លីត្រ) | 2833.0 | 3442.0 | 4004.0 | 4005.0 | 4750.8 | 3469.1 | 4163.0 | 4358.7 | 4415.5 | 4535.2 | 4750.1 | 5065.5 |

*Sources: NIS, NBC and CDRI*

## តារាង៧. ស្ថានភាពរូបិយវត្ថុ ឆ្នាំ២០០៦-១១ (តួលេខនៅចុងការិយបរិច្ឆេទ)

| | 2006 | 2007 | 2008 | 2009 | | | | 2010 | | | | 2011 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 |
| | ពាន់លានរៀល | | | | | | | | | | | |
| ទ្រព្យសកម្មបរទេសសុទ្ធ | 7224.0 | 10,735.0 | 10,345.0 | 11,222.0 | 12,611.0 | 13,869.0 | 14,655.0 | 15,514.6 | 12,610.9 | 16,903.0 | 16,697.9 | 17,079.1 |
| ទ្រព្យសកម្មក្នុងស្រុកសុទ្ធ | -282.0 | 576.0 | 1513.3 | 1266.0 | 1249.0 | 1042.0 | 1573.0 | 1720.0 | 1785.3 | 1984.8 | 2778.9 | 3199.2 |
| ឥណទេយ្យសុទ្ធលើរដ្ឋាភិបាល | -953.0 | -1816.0 | -2987.0 | -3048.0 | -2889.0 | -2463.0 | -2252.0 | -2484.8 | -2362.7 | -2,120.4 | -2126.6 | -2252.7 |
| ឥណទានដល់ផ្នែកឯកជន | 3630.0 | 6386.0 | 9894.0 | 9814.0 | 10,129.0 | 10,127.0 | 10,532.0 | 11,146.7 | 11,859.1 | 12,479.8 | 13,331.2 | 13,909.0 |
| រូបិយវត្ថុទូទៅ M2 | 6942.0 | 11,311.0 | 11,858.0 | 12,488.0 | 13,859.0 | 14,912.0 | 16,228.0 | 17,234.5 | 18,267.1 | 18,887.8 | 19,476.8 | 20,278.3 |
| រូបិយវត្ថុ M1 | 1658.0 | 2052.0 | 2399.0 | 2545.0 | 2695.0 | 2773.0 | 3120.0 | 3148.5 | 3115.1 | 3061.7 | 3220.9 | 3497.2 |
| រូបិយវត្ថុផ្សេងៗ | 5285.0 | 9259.0 | 9459.0 | 9942.0 | 11,164.0 | 12,139.0 | 13,108.0 | 14,086.0 | 15,152.0 | 15,826.1 | 16,255.9 | 16,781.1 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| រូបិយវត្ថុទូទៅ M2 | 38.1 | 62.9 | 4.8 | 3.7 | 9.1 | 18.7 | 36.9 | 38.0 | 31.8 | 26.7 | 20.0 | 17.7 |
| រូបិយវត្ថុ M1 | 25.3 | 23.8 | 16.9 | 6.5 | 9.2 | 18.7 | 30.1 | 23.7 | 15.6 | 10.4 | 3.2 | 11.1 |
| រូបិយវត្ថុផ្សេងៗ | 42.8 | 75.2 | 2.2 | 2.9 | 9.1 | 18.7 | 38.6 | 41.7 | 35.7 | 30.4 | 24.0 | 19.1 |

*Source: National Bank of Cambodia*

## តារាង៨. ចំណូលប្រចាំថ្ងៃជាមធ្យមពិតរបស់ពលករងាយរងគ្រោះ (ថ្លៃថេរ ខែវិច្ឆិកា ២០០០)

| | ចំណូលប្រចាំថ្ងៃ (ជារៀល) | | | | | | | | | បម្រែបម្រួលជាភាគរយធៀបឆ្នាំមុន | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2006 | 2007 | 2008 | 2009 | 2010 | | 2011 | | | 2011 | | |
| | | | | | សីហា | វិច្ឆិកា | កុម្ភៈ | ឧសភា | សីហា | កុម្ភៈ | ឧសភា | សីហា |
| អ្នកធាក់ស៊ីក្លូ | 7469 | 8075 | 12,628 | 8091 | 8404 | 8759 | 10,633 | 8,292 | 9,783 | 13.0 | -13.4 | 16.4 |
| អ្នកលីសែង | 6545 | 8588 | 9005 | 9549 | 10,525 | 9965 | 11,184 | 9861 | 10,465 | 12.4 | 5.6 | -0.6 |
| អ្នកលក់បន្លែតូចតាច | 6390 | 8220 | 9926 | 8273 | 8291 | 8821 | 9149 | 8599 | 8405 | 16.9 | 6.7 | 1.4 |
| អ្នករើសអេតចាយ | 4416 | 5422 | 4652 | 5857 | 6461 | 6628 | 6931 | 8661 | 7557 | 11.1 | 16.9 | 17.0 |
| អ្នកបម្រើតុភោជនីយដ្ឋាន* | 4412 | 4482 | 4327 | 4646 | 6427 | 5448 | 6154 | 6066 | 5410 | 19.9 | 12.7 | -15.8 |
| អ្នកស៊ីឈ្នួលធ្វើស្រែ | 5306 | 5516 | 8697 | 6197 | 6186 | 4912 | 4806 | 5984 | 7345 | -10.3 | -4.4 | 18.7 |
| កម្មកររោងចក្រកាត់ដេរ | 7649 | 7568 | 6554 | 7085 | 8470 | 7944 | 8312 | 7950 | 8687 | 10.0 | 6.1 | 2.6 |
| អ្នករត់ម៉ូតូឌុប | 8201 | 10,634 | 15,691 | 10,685 | 10,558 | 10,278 | 11,444 | 10,630 | 11,146 | 1.3 | 3.5 | 5.6 |
| កម្មករសំណង់គ្មានជំនាញ | 5918 | 6155 | 8779 | 8343 | 8744 | 9636 | 11,291 | 9415 | 10,526 | 46.7 | 4.5 | 20.4 |
| កម្មករសំណង់មានជំនាញ | 10,316 | 11,154 | 12,710 | 12,487 | 11,738 | 12,122 | 12,487 | 12,368 | 12,676 | 4.7 | 3.7 | 8.0 |

** Waitresses' earnings do not include meals and accommodation provided by shop owners. Surveys on the revenue of waitresses, rice-field workers, garment workers, unskilled workers, motorcycle taxi drivers and construction workers began in February 2000. Source: CDRI*

## Cambodia Development Review—2011 Subscription Rates

**Domestic Subscription (Individual)**

❒ English edition ($14) ❒ Khmer edition (5,000 riels) Payment by ❒ cash or ❒ local cheque (please add $2 to cover bank charges for processing local cheques). Total payment enclosed..........

**Domestic Subscription (Discount Price for Bulk Orders—Five Copies)**

❒ English edition ($60 for five copies) ❒ Khmer edition (20,000 riels for five copies) Payment by ❒ cash or ❒ local cheque (please add $2 to cover bank charges). Total payment enclosed..........

**International Subscription (Individual)**

| | | |
|---|---|---|
| ❒ Thailand, Laos, Vietnam | ❒ English edition ($25)* | ❒ Khmer edition ($15)* |
| ❒ Asia and Europe | ❒ English edition ($30)* | ❒ Khmer edition ($20)* |
| ❒ Americas and Africa | ❒ English edition ($35)* | ❒ Khmer edition ($25)* |

* Subscription includes postage. **Payment options:**

**1.** By Telegraphic Transfer – Please add $10 for bank charges to the above Total Cost.
Transfer to:
Account Name: CDRI
Account Number: 133451
Bank Name: ANZ Royal Bank
Bank Address: Phnom Penh, Cambodia
Swift Code: ANZBKHPP
Receiver Correspondent Bank: JP Morgan Chase Manhattan Bank, New York
Swift Code: CHASUS33
CHIP UID 004966

**2.** By Cheque - Please add (overseas) $50 for bank charges to the above Total Cost. Please make Cheque payable to CDRI, attach it to this invoice and send in to Publications.

Title: ❒Mr ❒Ms ❒Dr ❒ Other ..........
First name: .......... Last name: .......... Position: ..........
Organisation / Company: ..........
Address (CCC Box if applicable): ..........
City / Province: .......... Country: ..........
Telephone: .......... Fax: ..........
e-mail: .......... ❒ Tick to receive regular information about CDRI publications via e-mail

To subscribe, please fill in this form and return it to CDRI with your payment. Do not send cash through the post.
You will need to inform the Publishing Department at CDRI if your contact details change.